# របាយការណ៍ប្រចាំខែ ឧសភា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តប៊ុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.២ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- ថ្ងៃទី២៣ ខែមេសា លោកប្រធានមន្ទីរ ចូលរួមប្រជុំគណៈបញ្ជាការរដ្ឋបាលឯកភាពខេត្ត ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៤ ខែមេសា ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីចំនួន ០៤ រូប ចូលរួមប្រជុំការពិភាក្សាការងារ ជាមួយទីប្រឹក្សាគម្រោងសាខាកាកបាទក្រហមកម្ពុជា នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- ថ្ងៃទី២៧ ខែមេសា លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំត្រួតពិនិត្យ និងបូកសរុបលទ្ធផលការងារឆ្នាំ ២០១៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៥ របស់ក្រុមការងារថ្នាក់ជាតិ ចុះជួយមូលដ្ឋានខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៧ ខែមេសា មន្ត្រីចំនួន ០១ រូប ចូលរួមប្រជុំផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៨ ខែមេសា លោកប្រធានមន្ទីរ ចូលរួមប្រជុំបូកសរុបការងារសកម្មភាពប្រចាំឆ្នាំ២០១៤ និងលើកទិសដៅបន្តឆ្នាំ២០១៥ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២៩ ខែមេសា ថ្នាក់ដឹកនាំមន្ទីរបានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំខែមេសា របស់គណៈ

កម្មាធិកាពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ

- ថ្ងៃទី០៤ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ដោយគណៈកម្មាធិកាសម្របសម្រួលបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៥ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រជុំទី ០៩ ឆ្នាំ២០១៥ នៅសាលប្រជុំមន្ទីរផែនការ ខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៧ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី ១២ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៧ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមពិធីខួបអនុស្សាវរីយ៍លើកទី **១២៦** ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី១២ ខែឧសភា លោកប្រធានមន្ទីរ និងមន្ត្រីចំនួន ០៤ រូប ចូលរួមអមដំណើរឯកឧត្តមអភិបាលខេត្ត ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវ និងសាងសង់ផ្ទះនៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានគណៈកម្មាធិការអន្តរក្រសួង នៅភូមិតាមាន់សែនជ័យ ឃុំគោគមន ស្រុកបន្ទាយអំពិល (កងពលថ្មើរជើងលេខ ៤២)
- ថ្ងៃទី១៨ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីចំនួន ០៣ រូប ចូលរួមបុណ្យផ្កាប្រាក់រស្មីសាមគ្គី នៅវត្តសាមគ្គីមានជ័យ
- ថ្ងៃទី១៨ ខែឧសភា មន្ត្រីចំនួន ០១ រូប ចូលរួមប្រជុំស្តីពីការចុះប្រមូលព័ត៌មាន ដើម្បីរៀបចំផែនការសវនកម្ម និងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខេត្តឧត្តរមានជ័យ សម្រាប់ការិយបរិច្ឆេទ ២០១៤ នៅសាលប្រជុំសាលាខេត្ត
- នៅថ្ងៃទី១៩ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមក្នុងពិធីសប្បុរសធម៌កាកបាទក្រហមកម្ពុជា អបអរសាទរខួបលើកទី១៥២ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ ២០១៥ ក្រោមអធិបតីភាព ឯឧត្តម ឧត្តមសេនីយ៍ **គង់ គីម** សាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី២១ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមចុះអនុវត្តការងារវាស់វែង និងបែងចែកដីមួយផ្នែកនៃដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនទីរីងរ៉ាប់បើរ និងនៅចំនុចអូរអំបិល ស្រុកអន្លង់វែង ជូនប្រជាពលរដ្ឋដែលប៉ះពាល់ នៅសាលាស្រុកអន្លង់វែង
- ថ្ងៃទី២១ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំស្តីពី ការពង្រឹងភាពជាដៃគូ រវាងអង្គការជាតិ អន្តរជាតិ ជាមួយអាជ្ញាធរខេត្ត ដើម្បីឆ្លុះបញ្ចាំងនូវសកម្មភាពដែលបានអនុវត្តឆ្នាំ២០១៤ និងទិសដៅ

សម្រាប់អនុវត្តឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម លឹម សុខតូ អភិបាលរងខេត្ត នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ និង

- ថ្ងៃទី២១-២២ ខែឧសភា មន្ត្រីចំនួន ០៣ រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីក្នុងការរៀបចំធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិល នៅសាលប្រជុំមន្ទីរសុខាភិបាល ខេត្តឧត្តរមានជ័យ ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- កំពុងអនុវត្តការងារសាងសង់ផ្លូវថែទាំខួបឆ្នាំ២០១៥ ចាប់ពីភូមិគោកមន ឃុំគោកមន ដល់ភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ បានប្រវែងចំនួន ៩.២ គ.ម. ដោយកម្មវិធីគម្រោងឧបត្ថមស្បៀងបន្ទាន់ និង
- បញ្ចប់ការងារក្រាលគ្រួសក្រហម សរុបប្រវែង ៩.៣៩៧ ម រួមមាន÷ នៅស្រុកបន្ទាយអំពិល បានប្រវែង ២.៣៩៥ ម ស្រុកចុងកាល់ ប្រវែង ៤០០ ម ស្រុកអន្លង់វែង ប្រវែង ៣.៦៣២ ម និងក្រុងសំរោង ប្រវែង ២.៩៧០ ម ។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- បានចុះជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ០៣ កន្លែង រួមមាន÷ នៅមណ្ឌលសុខភាពស្រុកចុងកាល់ ០១ កន្លែង ភូមិពុរ សង្កាត់សំរោង ក្រុងសំរោង ០១ កន្លែង និងនៅភូមិឈើក្រំ សង្កាត់កូនក្រៀល ក្រុងសំរោង ០១ អណ្តូង និង
- បានចុះពិនិត្យអណ្តូងស្នប់ (VN6)ខូច នៅភូមិពុរ សង្កាត់សំរោង ចំនួន ០៣ អណ្តូង និងអណ្តូងស្នប់អាហ្វ្រីដេវខូចចំនួន ០៧ អណ្តូង នៅភូមិឈើក្រំ ០៣ អណ្តូង ភូមិចំប៉ាសុខ ០២ អណ្តូង និងភូមិគីរីវ័ន្ត ០២ អណ្តូង សង្កាត់កូនក្រៀល ក្រុងសំរោង ។

### ៣.៣ ការងារភូមិអភិវឌ្ឍន៍គំរូ

- បានបើកការដ្ឋានសាងសង់ផ្លូវក្រាលគ្រួសក្រហម ប្រវែង ៨.៤០០ ម និងលូ ២៧ កន្លែង នៅភូមិតាមាន់សែនជ័យ
- បានចុះជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវ ចំនួន ០៨ អណ្តូង និងស្រះសហគមន៍ ០១ កន្លែង (៤០ ម X ៣០ ម X ៣ ម ) នៅភូមិតាមាន់សែនជ័យ ឃុំគោកមន ស្រុកបន្ទាយអំពិល និងបានពិនិត្យអណ្តូងស្នប់អាហ្វ្រីដេវខូចចំនួន ០៦ អណ្តូង និង
- បានចុះជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ០៨ អណ្តូង រួមមាន÷ នៅភូមិតេជោដីក្រហម ០៣ អណ្តូង ភូមិតេជោ ថ្មល់កែង ០២ អណ្តូង ភូមិតេជោភូមិថ្មី ០២ អណ្តូង និងភូមិថ្មល់កែង ០១ អណ្តូង ស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ។

**៤. ទិសដៅការងារបន្ត**

- ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទប្រភេទទី ៣ និងទី ៤ នៅស្រុកបន្ទាយអំពិល
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ០២ អណ្តូង
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់ (VN6) ចំនួន ០៨ អណ្តូង
- កិច្ចសហការជាមួយអង្គការ (CHHRA) ស្តីពីការបណ្តុះបណ្តាលការសាងសង់អាងត្រងទឹកភ្លៀង និង
- រៀបចំប្រមូលទិន្នន័យអនាម័យភូមិ ចំនួន ៤៣ ភូមិ របស់កម្មវិធីអង្គការ Unicef ។